ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
*Nation- Religion- King*

រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

លេខ ៥១៧/២២ ក.អ.ក

ថ្ងៃអង្គារ ៤ រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ[illegible] ឆ្នាំ ២០២២

# សេចក្តីជូនដំណឹង
## ស្តីពី
## "វិធានការគ្រប់គ្រងការប្រើប្រាស់សារធាតុគីមីផ្សំគ្រឿងញៀននៅតាមបណ្តាក្រុមហ៊ុនវិនិយោគនានា"

យោងតាមលិខិតលេខ ០៣៩លស អ.ជ.ប.គ.ញ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានកិត្តិយសសូមជម្រាបជូនដល់អ្នកឧកញ៉ា-លោកឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ជាប្រធានក្រុមហ៊ុនវិនិយោគនានា ដែលបាននាំចូល និងប្រើប្រាស់នូវសារធាតុគីមីដែលអាចផ្សំជាគ្រឿងញៀន មេត្តាជ្រាបថា÷ ក្នុងស្មារតីពង្រឹងការគ្រប់គ្រងលើការប្រើប្រាស់នូវសារធាតុគីមីដែលអាចផ្សំជាគ្រឿងញៀន ឱ្យបានត្រឹមត្រូវតាមមុខសញ្ញាប្រើប្រាស់ពិតប្រាកដ សាមីក្រុមហ៊ុនទាំងអស់ត្រូវ÷

១- គ្រប់គ្រង និងប្រើប្រាស់សារធាតុគីមីដែលអាចផ្សំជាគ្រឿងញៀន សម្រាប់ប្រើប្រាស់ក្នុងខ្សែច្រវាក់ផលិតកម្មរបស់ខ្លួន ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងស្តង់ដារប្រើប្រាស់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

២- ប្រើប្រាស់សារធាតុគីមីដែលអាចផ្សំជាគ្រឿងញៀនឱ្យចំតាមគោលដៅដែលខ្លួនបានស្នើសុំ និងហាមលក់ដូរ ឬធ្វើអាជីវកម្មបន្តទៅឱ្យក្រុមហ៊ុនដទៃទៀត។

៣- មានអ្នកជំនាញបច្ចេកទេសច្បាស់លាស់ផ្នែកគីមី ដើម្បីគ្រប់គ្រង និងបញ្ជាប្រើប្រាស់សារធាតុគីមីដែលអាចផ្សំជាគ្រឿងញៀនសម្រាប់ខ្សែច្រវាក់ផលិតកម្មរបស់ខ្លួន។

៤- មានការកត់ត្រាច្បាស់លាស់អំពីបរិមាណនាំចូល បរិមាណប្រើប្រាស់ និងបរិមាណនៅសល់នូវសារធាតុគីមីដែលអាចផ្សំជាគ្រឿងញៀន ដើម្បីងាយស្រួលធ្វើការផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ។

៥- ធ្វើរបាយការណ៍ប្រចាំខែ ឆមាស និងឆ្នាំ អំពីការនាំចូលនាំចេញ និងការប្រើប្រាស់សារធាតុគីមីដែលអាចផ្សំជាគ្រឿងញៀន ជូនក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

សាមីក្រុមហ៊ុននឹងត្រូវប្រឈមនឹងការបាត់បង់ការលើកទឹកចិត្ត ព្រមទាំងប្រឈមនឹងទោសទណ្ឌផ្សេងៗទៀតស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ក្នុងករណីមិនគោរព ឬគោរពមិនបានត្រឹមត្រូវតាមការណែនាំដូចរៀបរាប់ខាងលើនេះ។

អាស្រ័យហេតុនេះ សូមអ្នកឧកញ៉ា-លោកឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ជាប្រធានក្រុមហ៊ុន មេត្តាអនុវត្តតាមការណែនាំដូចបានរៀបរាប់ដូចខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

**សូមអរគុណ!**

វិមានរដ្ឋាភិបាល វិថីព្រះស៊ីសុវត្ថិ វត្តភ្នំ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥)២៣-៧២៤ ៤៧៧ ទូរសារ : (៨៥៥) ២៣-៩៨១ ២៥៧
Government Palace, Sisowath Quay, Wat Phnom, Phnom Penh, Cambodia.
Tel:(855) 23-724 477, Fax (855) 23 981 257